# ការចិញ្ចឹមទា តាមបច្ចេកទេសបែបវិទ្យាសាស្ត្រធម្មជាតិ

## ១- ការជ្រើសរើសពូជ

1 – ជាទាជំនាន់ អ៊ី អ៊ិក្ស អ៊ិម ដែលបង្កើតឡើងដោយការភ្ញាស់ចេញពីពងទា អ៊ី  អ៊ិក្ស អ៊ិម ។

2 – ជ្រើសរើសយកកូនទាដែលមានឆ្អឹងរឹងមាំ ។

3 – ដងខ្លួនមានរាងជាចតុកោណស្មើ ។

4 – ឆ្អឹងគុម្ពកន្ទុយរន្ធគូថត្រូវឃ្លាតឆ្ងាយពីគ្នាចំពោះទាមេ  ចំណែកឯទាបាវិញត្រូវឆ្អឹងនៅជិតគ្នា ។

## ២- ការសង់ទ្រុងទា

1- ការសង់ទ្រុងទាត្រូវធ្វើឡើងនៅតាមបណ្តោយថ្ងៃ ។ បណ្តោយទ្រុង ១០ម៉ែត្រ និងទទឹង  ៤ម៉ែត្រ ។ ត្រូវចំនួន ២៥០ ទៅ ៥០០ក្បាល ។  ការធ្វើទ្រុងបែបនេះជាការចិញ្ចឹមតាមលក្ខណៈគ្រួសារ ។

2- ជុំវិញទ្រុងដែលសង់គួរតែយកស្បៃនីឡុងព័ទ្ធជុំវិញ  ឬយកសំណាញ់ដែកព័ទ្ធជុំវិញឬយកសំណាញ់ដែកព័ទ្ធជាការប្រសើរ  ដើម្បីការពារសត្វផ្សេងៗមកយាយីជីវិតសត្វទា និង ការចំលងមេរោគ ។

3- ចំពោះដំបូលទ្រុង  គួរតែប្រក់ស្លឹកធ្វើពីស្បូវ ជៀសវាងយកដែកមកប្រក់  ជាហេតុបណ្តាលអោយឡើងកំដៅនៅពេលរដូវក្តៅ ។

4- កំពស់រោងទា ប្រមាណ ១.៥ម៉ែត្រ ទៅ  ២ម៉ែត្រ ។

5- នៅក្នុងទ្រុងទាត្រូវក្រាលអង្កាមរស់ ឬមិនបាច់ក៏បានដែរ  បើក្រាលវាចំណេញការធ្វើជីអង្កាមរស់ដើម្បីយកទៅដាក់ស្រែ ។

## ៣- ការថែទាំកូនទា

1- កូនទាដែលញាស់បាន ១សប្តាហ៍ហើយ  ត្រូវយកមេ អ៊ី អ៊ិក្ស អ៊ិម បញ្ចូកក្នុង ១ក្បាល ១សេសេ ។

2- បើអាកាសធាតុប្រែប្រួលត្រជាក់ខ្លាំង យើងត្រូវយកក្តមមកចងព្យួរ  ដុតធ្យូងដើម្បីរក្សាសីតុណ្ហភាព បើសិនជាស្ថិតនៅក្នុងរដូវប្រាំងវិញ  លើផ្ទៃដែលកូនទារស់នៅមិនចាំបាច់ក្រាលអង្កាមទេ ។

3- យកមេ អ៊ី អ៊ិក្ស អ៊ិម ១លីត្រ  លាយជាមួយទឹកស្អាត ១០០០០លីត្រ អោយកូនទាផឹកជារៀងរាល់ថ្ងៃ ( ទឹកស្អាត ១០ លីត្រ  លាយមេអ៊ី អ៊ិក្ស អ៊ិម ១សេសេ ) ។ ទឹកដែលលាយនេះមិន អាចទុកលើសពី ២៤ម៉ោងទេ  បើទាផឹកមិនអស់ត្រូវជះទៅលើកន្លែងដែលមានក្លិនស្អុយហើយយើងចាប់ លាយសារជាថ្មីដោយអនុវត្តន៍តាមរបៀបនេះជារៀងរាល់ថ្ងៃ  បើសិនជាមានជំងឺក៏ ងាយស្រួលនឹងព្យាបាលដែរ ។

4- ឧស្សាហ៍ព្យាយាមសង្កេតមើលដំណើរសកម្មភាពទាទាំងឡាយនោះ បើទាណាមានការប្រែប្រួល  ត្រូវចាប់មកបញ្ចូកមេ អ៊ី អ៊ិក្ស អ៊ិម ចាប់ពី ១-៣សេសេ ចំពោះទា ១ក្បាល  ហើយទុកមួយកន្លែងសិន ។ បើសិនជាសះស្បើយហើយទើបយើងបញ្ចូលក្នុងហ្វូងវិញ  តែបើសិនជានៅមានបញ្ហាទៀតសូមទំនាក់ទំនងមកក្រុមហ៊ុនដើម្បីយកថ្នាំ បសុសត្វទៅព្យាបាល  ។

5- យកម្សៅសំរិទ្ធ ១កញ្ចប់តូច  លាយជាមួយចំណីមាន់ ៥គីឡូក្រាម ក្នុងមួយសប្តាហ៍ អោយមាន់ស៊ី ១ ឬ២ដង

6- យកម្សៅសំរិទ្ធ ១កញ្ចប់តូច  លាយជាមួយទឹកស្អាត ៥លីត្រ អោយមាន់ផឹកមួយសប្តាហ៍ ២ដង ។

7- នៅជុំវិញបរិវេណ  ដែលទាតែងតែរស់នៅ ( ទ្រុង មាត់ស្រះទឹក ទឹកស្រះ ) គួរតែបាញ់ អ៊ី អ៊ិក្ស  អ៊ិមបំផ្លាញបាក់តេរីអាក្រក់ក្នុង១សប្តាហ៍ ១ ទៅ ២ដង ទោះជាត្រូវកូនទា  ទាធំក៏ មិនអីដែរ ( ១:២៥០ ) ។ ការធ្វើបែបនេះបរិស្ថានរស់នៅរបស់ទាល្អ ទាជៀសផុតពីជំងឺផ្សេងៗ បើចង់បានផលការចិញ្ចឹមត្រូវយកចិត្តទុកដាក់ ។

៤- ករណីទាមានជំងឺ

1- ជំងឺទាទន់ជើង គេហៅថា ទាប៉ាប យើងប្រើមេ អ៊ី អិក្ស អិម បញ្ចូក១ក្បាល ៣សេសេ ក្នុង១ថ្ងៃ៣ដង បើមិនបាត់ត្រូវបញ្ចូកមេ អ៊ី អិក្ស អិម ១-២សេសេ លាយជាមួយបណ្ដេញ ពណ៌ខៀវ របស់ក្រុមហ៊ុន ១-២សេសេ ។ បើនៅតែមិនជា សូមប្រើថ្នាំបសុសត្វរបស់ក្រុមហ៊ុន ឈ្មោះអាមុក រឺទំនាក់ទំនងមកអ្នកជំនាញរបស់ក្រុមហ៊ុន ។

2- ជំងឺក្រហមភ្នែក សូមប្រើម្សៅវិទ្ធលាយជាមួយមេ អ៊ី អិក្ស អិម នឹងចំណីអាហារអោយទាស៊ី ។

3- ក្នុងករណីមានជំងឺផ្សេងៗទៀតលើសពីនេះ ឬប្រើប្រាស់ទៅមិនមានប្រសិទ្ធិភាព សូមទំនាក់ទំនងមកក្រុមការងាររបស់យើងខ្ញុំ (០២៣ ៨៨ ២៥ ៥៥) ។

---

ដកស្រង់ចេញពី៖

http://sopheapprom.wordpress.com/2011/10/08/%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%85%E1%9E%B7%E1%9E%89%E1%9F%92%E1%9E%85%E1%9E%B9%E1%9E%98%E2%80%8B%E1%9E%91%E1%9E%B6%E2%80%8B-%E2%80%8B%E1%9E%8F%E1%9E%B6%E1%9E%98%E2%80%8B%E1%9E%94%E1%9E%85%E1%9F%92/